**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥១ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយជំនាស់ដីធ្លីរវាង ប្រជាពលរដ្ឋនៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាមួយបញ្ជាការដ្ឋានធ័ពរថក្រោះ ACO

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យដោះស្រាយទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋនៅភូមិសំបួរ ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាមួយបញ្ជាការដ្ឋានកងទ័ពរថក្រោះ ACO នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- | ឯកឧត្តម **នុត សារាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- | ឯកឧត្តម **ទីម ជាសោភ័ណ** អគ្គនាយក នៃអគ្គនាយកដ្ឋានអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | អនុប្រធាន |
| ៣- | ឯកឧត្តម **កុល វិរក្ស** អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបា ។ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- | ឯកឧត្តមឧត្តមសេនីយ៍ ៗ **ឈឹង នរិន្ទ** អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ និងជានាយ ។ នៃនាយកដ្ឋានវិស្វកម្ម នៃក្រសួងការពារជាតិ | អនុប្រធាន |
| ៥- | ឯកឧត្តម **ខូច សារុន** អភិ លរងខេត្តកំពង់ស្ពឺ | អនុប្រធាន |
| ៦- | លោក **ធុ ផល្លា** អនុប្រធានអធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៧- | លោក **ឆេ ប៊ុនធឿន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៨- | លោក **ទេព មាន** អភិបាលស្រុកភ្នំស្រួច | សមាជិក |
| ៩- | លោក **ឈឹម សុផល** មន្ត្រីការិយាល័យផែនការក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |

**ប្រការ២** : គណៈកម្មការនេះមានភារកិច្ច :

- ចុះពិនិត្យ និង ស្រាវជ្រាវពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ៣១គ្រួសារ នៅភូមិសំបូរ ឃុំតាំងស្យា ស្រុកភ្នំស្រួច ដែលប្តឹងតវ៉ាជាមួយបញ្ជាការដ្ឋានទ័ពវ៉ៃក្រោះ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ។
- ធ្វើការសម្របសម្រួលរវាងភាគីទាំងពីរអោយមានការស្រុះស្រួលគ្នាប្រសិនបើអាចធ្វើបាន។ ក្នុងករណីមិនអាចសម្រុះសម្រួលគ្នាបាន ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផល នៃការស្រាវជ្រាវ និង លើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ៣** : គណៈកម្មការនេះមានសិទ្ធិអញ្ជើញអ្នកពាក់ព័ន្ធនៅមូលដ្ឋាន រួមទាំងអង្គភាព មន្ទីរ ឬ ស្ថាប័នពាក់ព័ន្ធ មកបំភ្លឺ និង ផ្តល់ឯកសារពាក់ព័ន្ធក្នុងក្របខណ្ឌសមត្ថកិច្ច និង ភារកិច្ច ដូចបានចែងក្នុងប្រការ២ ខាងលើ ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិបាលខេត្តកំពង់ស្ពឺ និង ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុង ប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

Royal Gov't Decision